គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ ៤២៨ ភ.ស.ណ /គ.ជ.អ.ប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០១០

**សូមជម្រាបជូន**
**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ : ការរៀបចំផ្ទេរធនធាន និងកិច្ចប្រតិបត្តិការនៃគណៈកម្មាធិការប្រតិបត្តិរាជធានី ខេត្ត**

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមជ្រាបថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានអនុម័តផែនការអនុវត្តន៍រយៈពេល៣ឆ្នាំ (ផអ៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅក្នុងកិច្ចប្រជុំលើកទី៥របស់ខ្លួន ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ កន្លងទៅនេះ។ ឯកសារផអ៣នេះ ត្រូវបានបង្ហាញ និងប្រឹក្សាយោបល់ជាមួយតំណាងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានារបស់យើងនៅក្នុងសិក្ខាសាលាជាតិ ដែលបានរៀបចំឡើងកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ ដែលតាមរយៈព្រឹត្តិការណ៍នេះ អង្គសិក្ខាសាលាទាំងមូលបានឯកភាពជាទូទៅក្នុងការឈានឆ្ពោះទៅរកការចាប់ផ្តើមអនុវត្តផែនការនេះ អាស្រ័យហេតុនេះ យើងត្រូវរៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១ឱ្យបានចប់សព្វគ្រប់ក្នុងពេលដ៏ខ្លីខាងមុខនេះ ដើម្បីពិភាក្សា និងអនុម័តជាមួយដៃគូអភិវឌ្ឍន៍របស់យើង។

ពាក់ព័ន្ធនឹងកិច្ចការខាងលើនេះ គ.ជ.អ.ប នឹងរៀបចំសិក្ខាសាលាជាតិមួយនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១១ ដោយមានការចូលរួមរបស់តំណាងរាជធានី និងខេត្តទាំងអស់ ដើម្បីធ្វើការណែនាំ និងពិភាក្សាអំពីការរៀបចំផ្ទេរធនធាន និងកិច្ចប្រតិបត្តិការនៃគណៈកម្មាធិការប្រតិបត្តិរាជធានី ខេត្ត ក្នុងដំណាក់កាលអន្តរកាល និងការកំណត់អំពីតួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ការរៀបចំបុគ្គលិកសម្រាប់អនុវត្តផអ៣ និងការវិភាជន៍ថវិកាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នអនុវត្តន៍នានានៅថ្នាក់ជាតិ។

ក្នុងពេលដ៏ខ្លីខាងមុខនេះ មុខងារនានាដែលធ្លាប់បានអនុវត្តដោយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ (គ.អ.ជ.ខ) និងគណៈកម្មាធិការប្រតិបត្តិ (គ.ប្រ) រាជធានី ខេត្ត នឹងត្រូវធ្វើការផ្ទេរជាផ្លូវការទៅឱ្យរដ្ឋបាលរាជធានី ខេត្តដែលទើបនឹងបង្កើតថ្មីដែលកិច្ចដំណើរការនេះ ចាំបាច់ត្រូវមានការបកស្រាយបំភ្លឺឱ្យបានច្បាស់លាស់នូវបញ្ហាសំខាន់មួយចំនួន។ ជារួមបញ្ហាទាំងនេះ នឹងត្រូវធ្វើការពិភាក្សាលម្អិតនៅក្នុងសិក្ខាសាលាជាតិនាខែមករា ប៉ុន្តែសម្រាប់ស្ថានភាពចំពោះមុខលេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការគូសបញ្ជាក់លើចំណុចសំខាន់ៗដូចខាងក្រោម :

## មុខតំណែងបុគ្គលិកបន្ថែមដែលត្រូវបំពេញមុខងារក្រោមក្របខ័ណ្ឌផអ៣

នៅក្នុងផអ៣ និងសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១ បានកំណត់នូវមុខតំណែងបុគ្គលិកថ្នាក់ក្រោមជាតិចំនួន២ប្រភេទ ដើម្បីជួយគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិនានា ដែលរួមមាន :



មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១/៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel : (855-23) 720 061 / 720 038

**ទីប្រឹក្សា :** មុខតំណែងទីប្រឹក្សានានា នឹងត្រូវធ្វើការជ្រើសរើស និងតែងតាំងដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធីពាក់ព័ន្ធនានាឱ្យទៅបំពេញការងារនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដើម្បីជួយគាំទ្រដល់រដ្ឋបាលទាំងអស់ក្នុងការបំពេញមុខងាររបស់ខ្លួន ព្រមទាំងជួយដល់លេខាធិការដ្ឋាន គ.ជ.អ.ប និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការអនុវត្ត និងតាមដានផអ៣។ តាមរយៈការឯកភាពគ្នាជាមួយ UNDP មុខតំណែងទីប្រឹក្សាភាគច្រើន ដែលមានបច្ចុប្បន្ននឹងត្រូវបន្តកិច្ចសន្យារបស់ពួកគេសម្រាប់រយៈពេល៣ខែរហូតដល់ចុងខែមីនា ឆ្នាំ២០១១។ ក្នុងរយៈពេលនេះ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធនានានឹងធ្វើការរៀបចំ ដើម្បីជ្រើសរើសទីប្រឹក្សាទាំងអស់សម្រាប់ដំណាក់កាលថ្មីចាប់ពីខែមេសាឆ្នាំ២០១១ ហើយទីប្រឹក្សាទាំងនេះនឹងត្រូវចុះកិច្ចសន្យាដោយផ្ទាល់ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័ននានាដែលជាភ្នាក់ងារអនុវត្តនីអនុកម្មវិធីនៃផអ៣។

**មុខតំណែងដែលត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភតាមប្រព័ន្ធ"ចំណាយប្រតិបត្តិការអាទិភាព" (ច.ប.អ) :** ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវមានមុខតំណែងមួយចំនួន ដែលត្រូវទទួលបាននូវការផ្តល់ប្រាក់ឧបត្ថម្ភតាមរយៈប្រព័ន្ធ "ចំណាយប្រតិបត្តិការអាទិភាព"។ មុខតំណែងទាំងនេះនឹងត្រូវអនុវត្តដោយបុគ្គលិកក្នុងទីចាត់ការនានារបស់សាលារាជធានី ខេត្ត ឬដែលអាចត្រូវបានបំពេញដោយមន្ត្រីរាជការស៊ីវិលរបស់មន្ទីរ អង្គភាពជំនាញនានា ជាពិសេសមន្ត្រីដែលធ្លាប់បំរើការងារជាមួយ គ.ប្រ តាមរយៈការជ្រើសរើសផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ប្រកបដោយតម្លាភាព និងស្របតាមគោលការណ៍ចំណាយប្រតិបត្តិការអាទិភាព។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការណែនាំលម្អិតអំពីនីតិវិធីនៃការជ្រើសរើសនេះ។

បញ្ជីមុខតំណែងដែលទទួលបាន ច.ប.អ និងមុខតំណែងទីប្រឹក្សា/មន្ត្រីកិច្ចសន្យានៅតាមរាជធានី និងខេត្តនីមួយៗ ដែលបានបញ្ចូលក្នុងផែនការសកម្មភាព និងថវិកាប្រចាំ ឆ្នាំ២០១១ មានជូនភ្ជាប់មកជាមួយ។

ដោយឡែក ពាក់ព័ន្ធនឹងការផ្ទេរការងារនៃផ្នែកនានារបស់ គ.ប្រ មកក្នុងប្រព័ន្ធ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំដូចខាងក្រោម :

## ១. សមាជិកអចិន្ត្រៃយ៍

ក្នុងដំណាក់កាលដំបូងនៃកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋបាលរាជធានី ខេត្តនឹងមានបន្ទុកការងារបន្ថែមជាច្រើន ដែលទាមទារឱ្យមានការជួយគាំទ្របន្ថែមដល់នាយករដ្ឋបាលរាជធានី ខេត្ត។ ដូច្នេះ មុខតំណែងមួយកន្លែងនៃ ច.ប.អ ត្រូវបានរៀបចំឡើងសម្រាប់សមាជិកអចិន្ត្រៃយ៍ ដើម្បីជួយគាំទ្រដល់អភិបាល និងនាយករដ្ឋបាលក្នុងការគ្រប់គ្រងការងារប្រចាំថ្ងៃនៃការអនុវត្តផអ៣។ មុខតំណែងនេះ គួរត្រូវផ្តល់ឱ្យនាយករងរដ្ឋបាលនៅក្នុងរដ្ឋបាលរាជធានី ខេត្ត ឬក៏ជាមន្ត្រីណាម្នាក់ដែលធ្លាប់មានបទពិសោធន៍ផ្នែកគ្រប់គ្រងជាមួយ គ.ប្រ។ ដូច្នេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើការជ្រើសរើសមុខតំណែងនេះដោយប្រុងប្រយ័ត្ន ដើម្បីធានាថាមន្ត្រីដែលនឹងត្រូវបានជ្រើសរើសសម្រាប់មុខតំណែងនេះមានសមត្ថភាព និងពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញការងារនេះ។

## ២. ផ្នែកហិរញ្ញវត្ថុ

ក្របខ័ណ្ឌផអ៣ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១ បានគ្រោងជ្រើសរើសបុគ្គលិកផ្នែកហិរញ្ញវត្ថុរបស់ គ.ប្រ ចំនួន១-៦នាក់ ដើម្បីបំរើការងារនៅក្នុងទីចាត់ការហិរញ្ញវត្ថុនៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីបន្តនិរន្តរភាពការងារ

ក្នុងការគ្រប់គ្រងគណនីប្រាក់ដុល្លារនានា ដោយរួមបញ្ចូលទាំងការទូទាត់ ការងារគណនេយ្យ ការងាររៀបចំរបាយការណ៍ និងសវនកម្ម ស្របតាមសៀវភៅណែនាំផ្នែកហិរញ្ញវត្ថុរបស់ គ.ជ.អ.ប ។ ទោះបីមន្ត្រីណាម្នាក់ក្នុងចំណោមមន្ត្រីទាំងនេះ ពុំបានបន្តចុះកិច្ចសន្យាការងារក្នុងទីចាត់ការហិរញ្ញវត្ថុនៃរដ្ឋបាលរាជធានី ខេត្តក៏ដោយ ក៏មន្ត្រីទាំងនេះនឹងត្រូវបានអញ្ជើញ ឱ្យមកចូលរួម និងស្រាយបំភ្លឺនៅពេលមានសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុដែលបានអនុវត្តដោយគ.ប្រ នារយៈពេល កន្លងមកតាមការចាំបាច់ ។

គណនីនានារបស់ គ.ប្រ ដែលមាននាពេលបច្ចុប្បន្ននឹងត្រូវបិទ ហើយគណនីថ្មីនឹងត្រូវបើកនៅដើមឆ្នាំ២០១១ ប៉ុន្តែចំពោះមុខ ការគ្រប់គ្រងគណនីប្រាក់ដុល្លារនេះ ចាំបាច់ត្រូវបន្តអនុវត្តដោយមន្ត្រីដែលមានបទពិសោធន៍ពីផ្នែកហិរញ្ញវត្ថុ របស់ គ.ប្រ និងត្រូវអនុវត្តស្របតាមសៀវភៅណែនាំផ្នែក ហិរញ្ញវត្ថុរបស់ គ.ជ.អ.ប ។ មន្ត្រីទាំងនេះនឹងទទួលបាននូវ ប្រាក់ឧបត្ថម្ភតាមរយៈប្រព័ន្ធ ច.ប.អ ។

ចំពោះ គណនេយ្យករឃុំ សង្កាត់នៅក្នុងរតនាគាររាជធានី ខេត្ត នឹងបន្តអនុវត្តមុខងាររបស់ខ្លួនជាធម្មតា ក្រោមការ ដឹកនាំរបស់រតនាគារជាតិ ។

## ៣. ផ្នែករដ្ឋបាលមូលដ្ឋាន

មន្ត្រីក្របខ័ណ្ឌក្រសួងមហាផ្ទៃនានាដែលធ្លាប់បំរើការងារនៅក្នុងផ្នែករដ្ឋបាលមូលដ្ឋាន ត្រូវបានផ្ទេរទៅក្នុងរចនា សម្ព័ន្ធថ្មីនៃរដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយ ។ ដោយឡែក ក៏រួមមានមន្ត្រីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតជាច្រើន ដែល ធ្លាប់បានបំរើការងារក្នុងផ្នែករដ្ឋបាលមូលដ្ឋាន ជាពិសេសមន្ត្រីសម្របសម្រួលរាជធានី ខេត្ត និងមន្ត្រីសម្របសម្រួលក្រុង ស្រុក ខណ្ឌ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការងារកំណែទម្រង់វិមជ្ឈការរបស់រាជរដ្ឋាភិបាល ។ ពាក់ព័ន្ធនឹងមន្ត្រីទាំងនេះ ផអ៣ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១ បានគ្រោងនូវមុខតំណែងជាច្រើន ដើម្បីបន្តការគាំទ្រដល់ថ្នាក់ ក្រុង ស្រុក ខណ្ឌ ដែលរួមមាន :

**ទីប្រឹក្សាកម្មវិធីជាតិថ្នាក់ក្រុង ស្រុក ខណ្ឌ :** មុខតំណែងនេះ នឹងត្រូវជ្រើសរើសសម្រាប់ក្រុង ស្រុក ខណ្ឌទាំង១៩៣ ដែលក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបានផ្តល់នូវទីប្រឹក្សាចំនួន០១រូប ។ មុខតំណែងនេះ នឹងទទួលបាននូវប្រាក់ឧបត្ថម្ភចំនួន ប្រមាណ៣០០ទៅ៤០០ដុល្លារក្នុងមួយខែ ហើយមន្ត្រីរាជការទាំងឡាយណាដែលត្រូវបានជ្រើសរើសសម្រាប់មុខតំណែងនេះ ត្រូវស្នើសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សពីអង្គភាពដើមរបស់ខ្លួន ។

**មន្ត្រីគាំទ្រឃុំ សង្កាត់ :** មន្ត្រីគាំទ្រឃុំ សង្កាត់ចំនួន០១នាក់ នឹងត្រូវជ្រើសរើសសម្រាប់គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ជាមធ្យមចំនួន៣ឃុំ សង្កាត់ ហេតុដូច្នេះ មុខតំណែងនេះមានចំនួនសរុប៥៤០នាក់ ដែលនឹងត្រូវជ្រើសរើសសម្រាប់បំពេញ ការងារនៅក្នុងការិយាល័យគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក ដើម្បីបន្តការងារជួយគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការ កសាងផែនការ ការរៀបចំថវិកា និងការអនុវត្ត ។ មុខតំណែងទាំងនេះនឹងទទួលបាននូវប្រាក់ឧបត្ថម្ភចំនួន៧០ដុល្លារក្នុង មួយខែតាមរយៈប្រព័ន្ធ ច.ប.អ ។

មុខតំណែងទាំងពីរខាងលើនេះ ត្រូវធ្វើការជ្រើសរើសជាប្រញាប់ ដែលលេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការណែនាំ អំពីដំណើរការនៃការជ្រើសរើសក្នុងពេលឆាប់ៗខាងមុខនេះ ។ មុខតំណែងនេះ នឹងផ្តល់ឱកាសដ៏ល្អមួយ សម្រាប់មន្ត្រីសម្រប សម្រួលរាជធានី ខេត្ត និងមន្ត្រីសម្របសម្រួលក្រុង ស្រុក ខណ្ឌ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំជាមួយអង្គភាពរដ្ឋបាល

មូលដ្ឋានក្នុងការបន្តការគាំទ្រដល់កំណែទម្រង់របស់រាជរដ្ឋាភិបាល។ លេខាធិការដ្ឋាន គ.ជ.អ.ប ស្នើសូមឯកឧត្តមអភិបាលរាជធានី ខេត្តទាំងអស់ ជួយជំរុញលើកទឹកចិត្តដល់មន្ត្រីសម្របសម្រួលរាជធានី ខេត្ត និងមន្ត្រីសម្របសម្រួលក្រុង ស្រុក ខណ្ឌ បន្តអនុវត្តនូវមុខងារបច្ចុប្បន្នរបស់ខ្លួន រហូតដល់ការជ្រើសរើសមុខតំណែងទាំងនេះ ត្រូវបានបញ្ចប់រួចរាល់។

## ៤. ផ្នែកគ្រប់គ្រងកិច្ចសន្យា

មុខងារដែលធ្លាប់បានអនុវត្តដោយផ្នែកគ្រប់គ្រងកិច្ចសន្យានាពេលបច្ចុប្បន្នរួមមាន ការងាររដ្ឋបាលទូទៅការគ្រប់គ្រងកិច្ចសន្យា ការតាមដាន និងការវាយតម្លៃ។ នៅក្នុងក្របខ័ណ្ឌផអ៣ និងផែនការសកម្មភាព និងថវិកាប្រចាំ ឆ្នាំ២០១១ បានគ្រោងមុខតំណែង ច.ប.អ ជាមធ្យមចំនួន០២នាក់នៅក្នុងទីចាត់ការរដ្ឋបាល ដើម្បីជួយកិច្ចការរដ្ឋបាលទូទៅ របស់ផអ៣ និងមុខតំណែង ច.ប.អ ជាមធ្យមចំនួន០៣នាក់នៅក្នុងទីចាត់ការផែនការ និងវិនិយោគ ដើម្បីជួយគាំទ្រការងារកសាងផែនការ ការតាមដាន និងវាយតម្លៃ។ មន្ត្រីផ្នែកគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ នាពេលបច្ចុប្បន្ន ក៏ដូចជាគ្រូឧទ្ទេសផ្នែកតាមដាន និងវាយតម្លៃ ដែលទទួលបានការបណ្តុះបណ្តាលអំពីការតាមដាន និងវាយតម្លៃអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ នឹងមានឱកាសល្អក្នុងការទទួលបាននូវការជ្រើសរើសជាមន្ត្រីកិច្ចសន្យាក្នុងការបំរើការងារនៅក្នុងទីចាត់ការទាំងពីរនេះដើម្បីគាំទ្រការអនុវត្តផអ៣។

## ៥. ផ្នែកគាំទ្របច្ចេកទេស

ក្របខ័ណ្ឌផអ៣ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១ បានផ្តល់លទ្ធភាពឱ្យមន្ត្រីគាំទ្របច្ចេកទេសចំនួន១៩៣នាក់នាពេលបច្ចុប្បន្ន បន្តការទទួលខុសត្រូវរបស់ខ្លួនក្នុងការជួយគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំប្លង់បច្ចេកទេសគម្រោង ការសិក្សាលទ្ធភាពគម្រោង ការដេញថ្លៃ និងការតាមដានការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនានា។ មន្ត្រីគាំទ្របច្ចេកទេសទាំងនេះ អាចបន្តចុះកិច្ចសន្យាបំរើការងារនៅក្នុងទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ហើយពួកគេនឹងទទួលបាននូវប្រាក់ឧបត្ថម្ភតាមរយៈប្រព័ន្ធ ច.ប.អ។ ក្នុងពេលពេលដ៏ខ្លីខាងមុខនេះ ក្រុមប្រឹក្សាឃុំ សង្កាត់នឹងបញ្ចប់នូវការរៀបចំផែនការថវិកាឆ្នាំ២០១១របស់ខ្លួន ដូច្នេះទាមទារឱ្យមានការគាំទ្រពីមន្ត្រីគាំទ្របច្ចេកទេសក្នុងការរៀបចំប្លង់បច្ចេកទេស និងការសិក្សាលទ្ធភាពគម្រោងនៅដើមឆ្នាំ២០១១។ ពាក់ព័ន្ធនឹងបញ្ហានេះ លេខាធិការដ្ឋាន គ.ជ.អ.ប ស្នើសូមឯកឧត្តមអភិបាលរាជធានី ខេត្តទាំងអស់មេត្តាជំរុញលើកទឹកចិត្តមន្ត្រីគាំទ្របច្ចេកទេសទាំងនេះ ដើម្បីបន្តអនុវត្តមុខងារបច្ចុប្បន្នរបស់ខ្លួនជាធម្មតា។

## ៦. អំពីសារពើភ័ណ្ឌ

សារពើភ័ណ្ឌទាំងអស់របស់ គ.ប្រ ត្រូវធ្វើការផ្ទេរទៅឱ្យសាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក និងសាលាខណ្ឌ។ តាមរយៈតារាងស្តីពីបុគ្គលិកថ្នាក់ក្រោមជាតិដែលមានជូនភ្ជាប់មកជាមួយ រាជធានី ខេត្តនីមួយៗ អាចដឹងពីចំនួនបុគ្គលិកដែលត្រូវផ្ទេរពី គ.ប្រ ចូលទៅក្នុងទីចាត់ការនីមួយៗនៃរចនាសម្ព័ន្ធសាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក និងសាលាខណ្ឌ។ ដូច្នេះ រាជធានី ខេត្តនីមួយៗ ត្រូវរៀបចំសេចក្តីព្រាងផែនការសារពើភ័ណ្ឌ ដែលបង្ហាញអំពីសំណើប្រើប្រាស់សារពើភ័ណ្ឌនៅតាមទីចាត់ការ និងការិយាល័យពាក់ព័ន្ធនីមួយៗ។ សេចក្តីព្រាងផែនការសារពើភ័ណ្ឌនេះ ត្រូវ

ផ្ញើជូនលេខាធិការដ្ឋាន គ.ជ.អ.ប តាមរយៈផ្នែករដ្ឋបាលនៃអង្គភាពគាំទ្រកម្មវិធី ដើម្បីធ្វើការពិនិត្យ និងធ្វើការណែនាំអំពីការធ្វើបច្ចុប្បន្នភាពនៃផែនការសារពើភ័ណ្ឌនេះ។ ដោយសារមានការផ្លាស់ប្តូរច្រើនក្នុងការអនុវត្តផអព ហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប អាចធ្វើការបែងចែងឡើងវិញនូវឧបករណ៍ និងសម្ភារៈមួយចំនួន ដើម្បីដោះស្រាយភាពខ្វះខាតនៅក្នុងខេត្តមួយចំនួន។

## ៧. ចំណាយប្រតិបត្តិការសម្រាប់ត្រីមាសទីមួយឆ្នាំ២០១១

សម្រាប់រយៈពេល៤ខែដំបូងក្នុងឆ្នាំ២០១១ ធនធានរបស់ គ.ជ.អ.ប សម្រាប់ចាប់ផ្តើមការអនុវត្តផអពនៅទូទាំងប្រទេសមានចំនួនតិចតួច ដោយផ្អែកជាសំខាន់លើមូលនិធិនានាដែលនៅសេសសល់ពីឆ្នាំ២០១០របស់គម្រោង PSDD និង គម្រោងផ្សេងទៀត។ អាស្រ័យហេតុនេះ យើងត្រូវរៀបចំគម្រោងថវិការបស់យើងដោយប្រុងប្រយ័ត្ន ដើម្បីធានាដល់ការគាំទ្រសកម្មភាពនានាដែលមានអាទិភាពខ្ពស់។ គណនីរបស់គម្រោង PSDD ដែលមាននៅក្នុង គ.ប្រ នឹងត្រូវបិទនៅចុងឆ្នាំ២០១០នេះ ហើយថវិកាដែលនៅសេសសល់នឹងត្រូវផ្ទេរមកលេខាធិការដ្ឋាន គ.ជ.អ.ប វិញ។ នាពេលខាងមុខឆាប់ៗនេះ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការណែនាំដល់រាជធានី ខេត្តទាំងអស់អំពីការបើកនូវគណនីថ្មីនៅក្នុងទីចាត់ការហិរញ្ញវត្ថុ ដើម្បីធ្វើការផ្ទេរមូលនិធិដំណាក់កាលដំបូងឱ្យរាជធានី ខេត្តនីមួយៗ។ ការរៀបចំចាំបាច់នានា និងការអនុម័តលើការផ្ទេរមូលនិធិក្នុងដំណាក់កាលដំបូងនេះ ទាមទារនូវពេលវេលាមួយសមស្រប ប៉ុន្តែលេខាធិការដ្ឋាន គ.ជ.អ.ប សង្ឃឹមថានឹងអាចផ្ទេរមូលនិធិនេះបាននៅពាក់កណ្តាលខែមករា ឆ្នាំ២០១១។ ចាប់ពីដើមឆ្នាំ២០១១ រហូតដល់មានការផ្ទេរមូលនិធិជាក់ស្តែង ចំណាយចាំបាច់នានាពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការនៅដើមឆ្នាំ២០១១ ត្រូវធ្វើឡើងដោយប្រើប្រាស់ថវិការបស់រាជធានី ខេត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមឯកឧត្តមមេត្តាសម្របសម្រួលកិច្ចដំណើរការទាំងនេះ ដើម្បីធានាបាននូវនិរន្តរភាពនៃកិច្ចប្រតិបត្តិការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លេខាធិការដ្ឋាន គ.ជ.អ.ប សង្ឃឹមថា បញ្ហាប្រឈមនានា នឹងត្រូវពិភាក្សាដោះស្រាយបន្ថែមទៀតនៅក្នុងសិក្ខាសាលានាថ្ងៃទី៥ ខែមករា ឆ្នាំ២០១១។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

សក់ សេដ្ឋា

**ចំនួនមុខតំណែងចំណាយប្រតិបត្តិការរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងជំអ៣**

| ល.រ | រាជធានី ខេត្ត | ចំនួនក្រុង ស្រុក ខណ្ឌ | សមាជិក អចិន្ត្រៃយ៍ (១) | ទីចាត់ការ រដ្ឋបាល | ទីចាត់ការធន ធានមនុស្ស | ទីចាត់ការ ហិរញ្ញវត្ថុ | ទីចាត់ការផែនការ និងវិនិយោគ | | មន្ត្រីក្រុមការងារ គណនេយ្យភាព | សវនករផ្ទៃក្នុង | ការិ.គាំទ្រ ឃុំ សង្កាត់ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ផ.ក/ M&E | ហេដ្ឋារចនាសម្ព័ន្ធ | | | | |
| 1 | បន្ទាយមានជ័យ | 9 | 1 | 2 | 2 | 3 | 3 | 9 | 2 | 1 | 21 | **53** |
| 2 | បាត់ដំបង | 14 | 1 | 2 | 2 | 5 | 5 | 14 | 2 | 1 | 31 | **77** |
| 3 | កំពង់ចាម | 17 | 1 | 3 | 3 | 6 | 6 | 17 | 3 | 1 | 59 | **116** |
| 4 | កំពង់ឆ្នាំង | 8 | 1 | 2 | 2 | 3 | 3 | 8 | 2 | 1 | 23 | **53** |
| 5 | កំពង់ស្ពឺ | 8 | 1 | 2 | 2 | 3 | 3 | 8 | 2 | 1 | 29 | **59** |
| 6 | កំពង់ធំ | 8 | 1 | 2 | 2 | 3 | 3 | 8 | 2 | 1 | 27 | **57** |
| 7 | កំពត | 8 | 1 | 2 | 2 | 3 | 3 | 8 | 2 | 1 | 31 | **61** |
| 8 | កណ្ដាល | 11 | 1 | 3 | 3 | 5 | 5 | 11 | 3 | 1 | 49 | **92** |
| 9 | កោះកុង | 7 | 1 | 1 | 1 | 2 | 2 | 7 | 1 | 1 | 9 | **32** |
| 10 | ក្រចេះ | 6 | 1 | 2 | 2 | 2 | 2 | 6 | 1 | 1 | 16 | **39** |
| 11 | មណ្ឌលគិរី | 5 | 1 | 1 | 1 | 2 | 2 | 5 | 1 | 1 | 7 | **26** |
| 12 | ភ្នំពេញ | 8 | 1 | 2 | 2 | 3 | 3 | 8 | 2 | 1 | 25 | **55** |
| 13 | ព្រះវិហារ | 8 | 1 | 2 | 2 | 3 | 3 | 8 | 1 | 1 | 17 | **46** |
| 14 | ព្រៃវែង | 13 | 1 | 3 | 3 | 4 | 4 | 13 | 3 | 1 | 40 | **85** |
| 15 | ពោធិ៍សាត់ | 6 | 1 | 2 | 2 | 2 | 2 | 6 | 1 | 1 | 16 | **39** |
| 16 | រតនគិរី | 9 | 1 | 2 | 2 | 3 | 3 | 9 | 1 | 1 | 16 | **47** |
| 17 | សៀមរាប | 12 | 1 | 3 | 3 | 4 | 4 | 12 | 3 | 1 | 33 | **76** |
| 18 | ព្រះសីហនុ | 4 | 1 | 1 | 1 | 2 | 2 | 4 | 1 | 1 | 9 | **26** |
| 19 | ស្ទឹងត្រែង | 5 | 1 | 2 | 2 | 2 | 2 | 5 | 1 | 1 | 11 | **32** |
| 20 | ស្វាយរៀង | 8 | 1 | 2 | 2 | 3 | 3 | 8 | 2 | 1 | 26 | **56** |
| 21 | តាកែវ | 10 | 1 | 3 | 3 | 3 | 3 | 10 | 3 | 1 | 33 | **70** |
| 22 | ឧត្តរមានជ័យ | 5 | 1 | 2 | 2 | 2 | 2 | 5 | 1 | 1 | 8 | **29** |
| 23 | កែប | 2 | 1 | 1 | 1 | 1 | 1 | 2 | 1 | 1 | 2 | **13** |
| 24 | ប៉ៃលិន | 2 | 1 | 1 | 1 | 1 | 1 | 2 | 1 | 1 | 2 | **13** |
| | **សរុប** | **193** | **24** | **48** | **48** | **70** | **70** | **193** | **42** | **24** | **540** | **1,252** |

(១) : អាចជានាយករងរដ្ឋបាល ឬមន្ត្រីដែលមានសមត្ថភាពក្នុងការសម្របសម្រួល និងដឹកនាំការងារប្រចាំថ្ងៃ

## ចំនួនទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាថ្នាក់ក្រោមជាតិ

| ល.រ | រាជធានី ខេត្ត | ទីប្រឹក្សាកម្មវិធីជាតិ ថ្នាក់រាជធានី ខេត្ត | មន្ត្រីតាមដាន និងវាយតម្លៃ | ទីប្រឹក្សា អភិវឌ្ឍសមត្ថភាព | ទីប្រឹក្សា ហិរញ្ញវត្ថុ | ទីប្រឹក្សា ហេដ្ឋារចនាសម្ព័ន្ធ | ទីប្រឹក្សា IT ខេត្ត | ទីប្រឹក្សាកម្មវិធីជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ | មន្ត្រី IT ក្រុង ស្រុក ខណ្ឌ | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | 1 | 2 | 2 | 1 | 1 | 1 | 9 | 9 | 26 |
| 2 | បាត់ដំបង | 1 | 2 | 1 | 1 | 2 | 1 | 14 | 14 | 36 |
| 3 | កំពង់ចាម | 1 | 3 | 3 | 1 | 2 | 1 | 17 | 17 | 45 |
| 4 | កំពង់ឆ្នាំង | 1 | 2 | 2 | 1 | 1 | 1 | 8 | 8 | 24 |
| 5 | កំពង់ស្ពឺ | 1 | 2 | 2 | 1 | 1 | 1 | 8 | 8 | 24 |
| 6 | កំពង់ធំ | 1 | 2 | 2 | 1 | 1 | 1 | 8 | 8 | 24 |
| 7 | កំពត | 1 | 2 | 2 | 1 | 1 | 1 | 8 | 8 | 24 |
| 8 | កណ្តាល | 1 | 2 | 2 | 1 | 2 | 1 | 11 | 11 | 31 |
| 9 | កោះកុង | 1 | 1 | 2 | 1 | 1 | 1 | 7 | 7 | 21 |
| 10 | ក្រចេះ | 1 | 1 | 2 | 1 | 1 | 1 | 6 | 6 | 19 |
| 11 | មណ្ឌលគិរី | 1 | 1 | 2 | 1 | 1 | 1 | 5 | 5 | 17 |
| 12 | ភ្នំពេញ | 1 | 2 | 2 | 1 | 1 | 1 | 8 | 8 | 24 |
| 13 | ព្រះវិហារ | 1 | 1 | 2 | 1 | 1 | 1 | 8 | 8 | 23 |
| 14 | ព្រៃវែង | 1 | 3 | 3 | 1 | 1 | 1 | 13 | 13 | 36 |
| 15 | ពោធិ៍សាត់ | 1 | 1 | 2 | 1 | 1 | 1 | 6 | 6 | 19 |
| 16 | រតនគិរី | 1 | 2 | 2 | 1 | 1 | 1 | 9 | 9 | 26 |
| 17 | សៀមរាប | 1 | 2 | 2 | 1 | 1 | 1 | 12 | 12 | 32 |
| 18 | ព្រះសីហនុ | 1 | 1 | 2 | 1 | 1 | 1 | 4 | 4 | 15 |
| 19 | ស្ទឹងត្រែង | 1 | 2 | 2 | 1 | 1 | 1 | 5 | 5 | 18 |
| 20 | ស្វាយរៀង | 1 | 1 | 2 | 1 | 1 | 1 | 8 | 8 | 23 |
| 21 | តាកែវ | 1 | 2 | 2 | 1 | 1 | 1 | 10 | 10 | 28 |
| 22 | ឧត្តរមានជ័យ | 1 | 1 | 2 | 1 | 1 | 1 | 5 | 5 | 17 |
| 23 | កែប | 1 | 1 | 0 | 0 | 0 | 1 | 2 | 2 | 7 |
| 24 | ប៉ៃលិន | 1 | 1 | 0 | 1 | 0 | 1 | 2 | 2 | 8 |
| | **សរុប** | **24** | **40** | **45** | **23** | **25** | **24** | **193** | **193** | **567** |